# ប្រជាជនស្នើដល់អាជ្ញាធរសង្កាត់ព្រែកប្រាជួយទប់ស្កាត់ក្រុមហ៊ុនបូមខ្សាច់និងបញ្ហាប្រឈមមួយចំនួន



*លោកហួរ ហួត ចៅសង្កាត់ព្រែកប្រា ពេលចុះធ្វើវេទិកាសាធារណៈ ជួប-ទទួលសំណើប្រជាជន (រូបថតៈសុវណ្ណភូមិ)*

**ភ្នំពេញ ៖** ប្រជាជននៅភូមិបឹងព្រលឹត សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ ក្រុងភ្នំពេញ បានលើកឡើងជាសំណូមពរទៅក្នុងវេទិកាសាធារណៈកាលពីព្រឹកថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៤នេះ ដោយស្នើទៅដល់អាជ្ញាធរសង្កាត់ ប៉ូលិសប៉ុស្តិ៍ជួយដោះស្រាយបញ្ហាប្រឈមដែលកំពុងយាយីដល់ពួកគាត់នាបច្ចុប្បន្ននេះ ដូចជាបញ្ហាចោរកម្ម ក្រុមក្មេងទំនើងអុកឡុកមូលដ្ឋាន ជួយស្តារប្រព័ន្ធលូ ដាក់ភ្លើងបំភ្លឺផ្លូវពេលយប់ ជួយទប់ស្កាត់ក្រុមហ៊ុនបូមខ្សាច់លុបបឹងធម្មជាតិបង្កការលិចលង់ដល់លំនៅស្ថានពួកគាត់ បញ្ហាលក់ដូរអីវ៉ាន់ហូរហៀរលើកំណាត់ផ្លូវសាធារណៈ (ផ្សារចាម) បញ្ហាបរិស្ថានផ្សារចាមធ្វើឱ្យប៉ះពាល់ដល់សុខភាព ។ល។

ចំពោះសំណើលើកឡើងរបស់ប្រជាជនខាងលើនេះ លោក ហួរ ហួត ចៅសង្កាត់ព្រែកប្រាបានទទួលយកទាំងអស់ដើម្បីដោះស្រាយជូនប្រជាជន និងរាយការណ៍ជូនថ្នាក់លើផងដែរ ។

ជាមួយគ្នានេះ លោកហួរ ហួត ចៅសង្កាត់ព្រែកប្រាគាត់ក៏បានលើកឡើងពីការអភិវឌ្ឍន៍ភូមិ-សង្កាត់នាពេលបច្ចុប្បន្ននេះថា មានការអភិវឌ្ឍន៍លើគ្រប់វិស័យគួរចាប់អារម្មណ៍ពេញភូមិ-សង្កាត់ មានផ្លូវបេតុងខ្វាត់ខ្វែងពេញភូមិ ។

លោកចៅសង្កាត់ព្រែកប្រាបន្តទៀតថា រាល់សមិទ្ធផលកើតឡើងនាពេលនេះជាការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រប្រជាជនផងដែរ។

លោកហួរ ហួត ចៅសង្កាត់ព្រែកប្រាបានលើកឡើងផ្សព្វផ្សាយពីគោលនយោបាយភូមិ-សង្កាត់មានសុវត្ថិភាពជូនប្រជាជនបានយល់ដឹងផងដែរ។

**សុវណ្ណភូមិ**